云南日报 YUNNAN DAILY PRESS GROUP 云南日报报业集团 No.177

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំខែ

khmerlight@163.com
english.yunnan.cn

ឆ្នាំទី27 លេខ7897 ថ្ងៃសុក្រ ទី29 ខែមីនា ឆ្នាំ2019

## លេខាបក្ស និងអភិបាលខេត្តយូនណានឆ្លើយសំណួរអ្នកសារព័ត៌មាន




*លោកឆឹន ហាវ លេខាធិការ គណបក្សនៃគណ:កម្មាធិការបក្ស កុម្មុយនិស្តចិនខេត្តយូនណាន*

នៅថ្ងៃទី៧ ខែមីនា ឆ្នាំ ២០១៩ គណ:ប្រតិភូខេត្តយូណានបានរៀបចំកិច្ចប្រជុំពេញអង្គក្នុងឱកាសកិច្ចប្រជុំលើកទី២នៃសភាតំណាងប្រជាជនទូទាំងប្រទេសចិននីតិកាលទី១៣ ។ អ្នកសារព័ត៌មាន៩៣នាក់ ដែលមកពីអង្គភាពសារព័ត៌មានចិននិងបរទេសចំនួន៤៨បានចូលរួមនិងយកបទសម្ភាសន៍ក្នុងកិច្ចប្រជុំនេះ ។ ក្នុងកិច្ចប្រជុំនេះតើអ្នកសារព័ត៌មានយកចិត្តទុកដាក់ចំពោះបញ្ហាអ្វីជាងគេ? ពេលនេះយើងខ្ញុំសូមជ្រើសរើសសំណួរសំខាន់ៗនិងចម្លើយរបស់ថ្នាក់ដឹកនាំបង្ហាញជូនលោកអ្នកដើម្បីធ្វើឱ្យលោកអ្នកមានការយល់ដឹងកាន់តែស៊ីជម្រៅអំពីខេត្តយូនណាន ។

-អ្នកសារព័ត៌មាននៃស្ថានីយទូរទស្សន៍ជាតិចិន:ខេត្តយូណានជាសមរភូមិសំខាន់នៃយុទ្ធនាការកាត់បន្ថយភាពក្រីក្ររបស់ប្រទេសយើង។ សូមសួរថា រដ្ឋបាលខេត្តយូនណាននឹងចាត់វិធានការអ្វីខ្លះដើម្បីសម្រេចនូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រព្រមជាមួយតំបន់ផ្សេងៗទៀតក្នុងប្រទេសចិន?

លោកឆឹន ហាវ លេខាធិការគណបក្សនៃគណ:កម្មាធិការបក្សកុម្មុយនិស្តចិនខេត្តយូនណាន :ក្រោយពីសមាជបក្សកុម្មុយនិស្តចិនលើកទី១៨ រៀងមក យើងខ្ញុំបានប្រកាន់ខ្ជាប់នូវគោលការណ៍មូលដ្ឋានអំពីការកាត់បន្ថយភាពក្រីក្រដោយតម្រង់ទិស ដើម្បីជំរុញឱ្យការងារកាត់បន្ថយភាពក្រីក្រសម្រេចបាននូវប្រសិទ្ធភាពខ្ពស់ ។ ក្នុងអំឡុងពេលពីឆ្នាំ២០១៣ដល់ឆ្នាំ២០១៨ យើងបានជួយប្រជាជនក្រីក្រ៧,០៧លាននាក់កាត់បន្ថយភាពក្រីក្រ ។ នៅឆ្នាំ២០១៧យើងបានកាត់បន្ថយភាពក្រីក្រឱ្យស្រុកចំនួន១៥ ។ នៅឆ្នាំ ២០១៨ យើងបានជួយប្រជាជនក្រីក្រ១,៥១ លាននាក់ ភូមិក្រីក្រចំនួន២២៩៨ ភូមិ និងស្រុកក្រីក្រចំនួន ៣៣ស្រុក កាត់បន្ថយភាពក្រីក្រ ។ ជនជាតិទូឡុង ជនជាតិគីណូជនជាតិតឺអាងនិងជនជាតិភាគតិចមួយចំនួនទៀត ដែលមានប្រជាជនតិចបានកាត់បន្ថយភាពក្រីក្រទាំងស្រុងដែលមានសារសំខាន់ជាប្រវត្តិសាស្ត្រក្នុងបុព្វហេតុនៃការកាត់បន្ថយភាពក្រីក្ររបស់ខេត្តយូណាន ។ ប៉ុន្តែសព្វថ្ងៃខេត្តយូនណាននៅមានប្រជាជនក្រីក្រចំនួន១,៨១លាននាក់ ស្រុកក្រីក្រចំនួន៤០ស្រុក និងភូមិក្រីក្រចំនួន ៣៤៣៤ភូមិ ។ យើងខ្ញុំនឹងផ្តោតសំខាន់ទៅលើការងារកាត់បន្ថយភាពក្រីក្រនៃតំបន់ក្របំផុតតាមរយ:ការផ្តល់ថវិកានិងចាត់វិធានការដ៏មានប្រសិទ្ធភាព ដើម្បីទទួលជ័យជម្នះក្នុងយុទ្ធនាការនៃការកាត់បន្ថយភាពក្រីក្រដោយតម្រង់ទិស។ នៅឆ្នាំ២០២០ ប្រជាជនគ្រប់ជន ជាតិនៅខេត្តយូនណាននឹងជៀសផុតពីបញ្ហាក្រីក្រហើយឈានចូលសង្គមធូរធារជាមួយប្រជាជនទូទាំងប្រទេស ចិន។

-អ្នកកាសែតនៃកាសែតចិនដេលី: ក្នុងរយ:ពេល២ឆ្នាំកន្លងទៅនោះ ខេត្តយូនណានបានចាត់វិធានការតឹងរ៉ឹងបំផុតដែលបានសម្រេចនូវការផ្លាស់ទម្រង់អភិវឌ្ឍន៍នៃវិស័យទេសចរណ៍ ហើយ បានទទួលនូវចំណូល ។ បន្ទាប់ពីនោះខេត្តយូនណាននឹងចាត់វិធានការអ្វីខ្លះ ដើម្បីសម្រេចនូវការធ្វើបដិវត្តន៍ទេសចរណ៍? កម្មវិធីAPP "ដើរលេងខេត្តយូនណានដោយប្រើទូរស័ព្ទតែមួយគ្រឿង"នឹងត្រូវកែលម្អនិង មានមុខងារថ្មីអ្វីខ្លះ?

លោក យាន់ ឈឹងហ្វា អភិបាលខេត្តយូនណាន :ក្រោយពីបានចាត់វិធានការគ្រប់គ្រងថ្មីទីផ្សារទេសចរណ៍នៃខេត្តយូនណានកំពុងមានសណ្តាប់ធ្នាប់កាន់តែល្អប្រសើរ ។ នៅឆ្នាំ ២០១៨ ប្រព័ន្ធទទួលការប្តឹងតវ៉ាអំពីវិស័យទេសចរណ៍បានទទួលការប្តឹងតវ៉ា ៧៨០ករណីដែលមានពាក់ព័ន្ធនឹងខេត្តយូនណានធ្លាក់ចុះ៥៣ភាគរយ ធៀបនឹងឆ្នាំ២០១៧ ។ ចំនួនទេសចរនិងចំណូលទេសចរណ៍របស់ខេត្តយូនណានបានកើនឡើងជាង២០ ភាគរយ ។ យើងនឹងចាត់វិធានការគ្រប់គ្រងថ្មីនិងជំរុញការផ្លាស់ទម្រង់អភិវឌ្ឍន៍ដើម្បីជំរុញឱ្យវិស័យទេសចរណ៍ខេត្តយូនណានសម្រេចនូវអន្តរជាតូបនីយកម្មមានកម្រិតខ្ពស់មានលក្ខណៈពិសេសនិងបំពាក់ដោយប្រព័ន្ធវៃឆ្លាត។ សព្វថ្ងៃប្រព័ន្ធទេសចរណ៍វៃឆ្លាតដែលតំណាងដោយកម្មវិធីAPP "ដើរលេងខេត្តយូនណានដោយប្រើទូរស័ព្ទតែមួយគ្រឿង"នោះ បានទទួលនូវសមិទ្ធផលមួយចំនួន ។ នៅពេលខាងមុខយើងខ្ញុំនឹងផ្តោតសំខាន់ទៅលើការងារចំនួន២ ។ យើងនឹងខិតខំកែលម្អសេវាកម្មដែលផ្តល់ដល់អ្នកទេសចរតាមរយ:កម្មវិធី APPនេះហើយសម្រេចនូវការប្រើប្រាស់ APP នេះតាមបណ្តាញ5G ។ ម៉្យាងទៀត យើងនឹងខិតខំធ្វើការងាររដ្ឋបាលឱ្យបានល្អនៅឆ្នាំនេះ ពីព្រោះមានតែស្ថាប័នរដ្ឋបាលផ្តល់សេវាកម្មពេញលក្ខណៈទើបអ្នកទេសចរអាចធ្វើដំណើរដោយពេញចិត្ត ។

-អ្នកសារព័ត៌មានដែលមកពីកាសែតតាកុង វិនហ្វយ តំបន់ហុងកុង : ខេត្តយូណានបានលើកឡើងថា នឹងកសាងខេត្តស្រស់ស្អាតជាងគេក្នុងប្រទេសចិនតើពាក្យថា"ខេត្តស្រស់ស្អាតជាងគេ"នេះមានអត្ថន័យអ្វីខ្លះ? ហេតុអ្វីបានជាខេត្តយូនណានមានជំនឿចិត្តលើការកសាងខេត្តស្រស់ស្អាតជាងគេ?

លោកឆឹន ហាវលេខាធិការគណបក្សនៃគណ:កម្មាធិការបក្សកុម្មុយនិស្តចិនខេត្តយូនណាន:យើងនឹងកសាងខេត្តយូនណានឱ្យទៅជាខេត្តដែលស្រស់ស្អាតជាងគេក្នុងប្រទេសចិន ពោលគឺមានអេកូ-ធម្មជាតិស្អាតមានបរិស្ថានស្អាតមានទឹកនិងភ្នំស្អាតមានទីក្រុងស្អាត និងមានជនបទស្អាត ។

យើងមានជំនឿចិត្តមានមូលដ្ឋានរឹងមាំនិងមានកម្លាំងគ្រប់គ្រាន់ក្នុងការកសាងខេត្តយូណានឱ្យទៅជាខេត្តដែលស្រស់ស្អាតជាងគេក្នុងប្រទេសចិន ។ យើងមានសម្បត្តិដ៏មានតម្លៃដែលបន្សល់ទុកដោយដូនតាយើងមាននាមប័ណ្ណសំខាន់ចំនួន៤គឺ "ខេត្តយូនណានដ៏ចម្រុះពណ៌ឋានសួគ៌ទេសចរណ៍" "ខេត្តយូនណានដូចគំនូរវប្បធម៌ដ៏មានតម្លៃ" "កន្លែងលំហែកាយថែរក្សាសុខភាព"និង"តំបន់ឈានមុខនៃការបើកទូលាយមជ្ឈមណ្ឌលនាំផ្លូវអភិវឌ្ឍន៍" ។ ប៉ុន្មានឆ្នាំមកនេះយើងបានប្រកាន់ខ្ជាប់នូវគោលការណ៍អភិវឌ្ឍន៍ដោយបៃតងនិងផ្តល់អាទិភាពដល់ការការពារបរិស្ថានខិតខំដោះស្រាយបញ្ហាបំពុលបរិស្ថានព្រមទាំងជំរុញការការពារអេកូ-ធម្មជាតិ ។ អត្រានៃថ្ងៃដែលមានគុណភាពអាកាសធាតុល្អនៅទីក្រុងទាំងអស់ក្នុងខេត្តយូនណានមានចំនួន ៩៨,៩ភាគរយ ជាប់លំដាប់លេខ១ ក្នុងប្រទេសចិន២ឆ្នាំជាប់គ្នាហើយមានទេសចរជាតិនិងអន្តរជាតិកាន់តែច្រើនមកទទួលខ្យល់បរិសុទ្ធភ្លក់អាហារឆ្ងាញ់ៗ និងគយគន់ទេសភាពធម្មជាតិនៅខេត្តយូនណាន ៕



*អ្នកសារ ព័ត៌មាន៩៣នាក់ដែលមកពីអង្គភាព សារព័ត៌មានចិននិងបរទេសចំនួន ៤៨ បានចូលរួមកិច្ចប្រជុំ និងធ្វើសម្ភាសន៍ជា មួយតំណាងខេត្តយូណាន*

## ប្រទេសចិនសម្រេចកំណើនពាណិជ្ជកម្មនាំចេញនាំចូលដោយមានស្ថិរភាព



*រថភ្លើងចិន-អឺរ៉ុបធ្វើ ដំណើរឆ្លងកាត់ស្ថានីយរថភ្លើងស៊ុយហ៊ឺ ខាងលិចក្នុងទីក្រុងអ៊ូឡានឆាពូ នៃខេត្តម៉ុងហ្គោលីក្នុង (កាសែតប្រជាជនដេលី)*

តាមស្ថិតិប្រទេសចិនបានសម្រេចទំហំពាណិជ្ជកម្មនាំចេញនាំចូលជាង ៣០ទ្រីលានយ័ននៅឆ្នាំ២០១៨ ដែលបានបង្កើតឯតទគ្គកម្មថ្មី។ ប្រទេសចិនបានរក្សាស្ថិរភាពពាណិជ្ជកម្ម និងបានទទួលការរីកចម្រើនគួរឱ្យកត់សម្គាល់ ហើយនឹងអាចរក្សាតួនាទីជាប្រទេសធំជាងគេក្នុងការធ្វើពាណិជ្ជកម្មទំនិញ។ ក្រោយពីខ្សែរថភ្លើងចិន-អឺរ៉ុប ត្រូវបានដាក់ឱ្យប្រើប្រាស់នៅឆ្នាំ២០១១រៀងមក ខ្សែរថភ្លើងនេះ បានទទួលការរីកចម្រើនយ៉ាងឆាប់រហ័សហើយបានជំរុញការអភិវឌ្ឍនៃពាណិជ្ជកម្មនាំចេញនាំចូលរបស់ប្រទេសចិន។ តាមស្ថិតិពីអគ្គនាយកដ្ឋានគយចិនគិតមកដល់ចុងឆ្នាំ ២០១៨ រថភ្លើង១០.៧៥២គ្រឿងបានធ្វើដំណើរតាមខ្សែរថភ្លើងចិន-អឺរ៉ុបក្រោមការគ្រប់គ្រងនៃស្ថាប័នគយ៕

## វេទិកាឃ្លាំងគំនិតខ្សែ ក្រវាត់អភិវឌ្ឍន៍សេដ្ឋកិច្ចទន្លេឡានឆាង-មេគង្គប្រារព្ធនៅក្រុងគុនមីង

ពេលថ្មីៗនេះ វេទិកាឃ្លាំងគំនិតខ្សែក្រវាត់អភិវឌ្ឍន៍សេដ្ឋកិច្ចទន្លេឡានឆាង-មេគង្គ បានប្រារព្ធនៅក្រុងគុនមីង ខេត្តយូនណានប្រទេសចិន។

វេទិកានេះរៀបចំក្រោមប្រធានបទ "កសាងខ្សែក្រវាត់អភិវឌ្ឍន៍ សេដ្ឋកិច្ចទន្លេឡានឆាង-មេគង្គ" ដើម្បី ជំរុញការអភិវឌ្ឍនៃយន្តការស្តីពីកិច្ចសហប្រតិបត្តិការទន្លេឡានឆាង-មេគង្គ និងបង្កើនការផ្លាស់ប្តូរជាមួយគ្នា។

វេទិកានេះចែកជា៥ផ្នែក គឺ "ទ្រឹស្តី និងការអនុវត្តជាក់ស្តែងអំពីការកសាងខ្សែក្រវាត់អភិវឌ្ឍន៍សេដ្ឋកិច្ច" "គំនិត និងមធ្យោបាយអំពីការកសាងខ្សែក្រវាត់អភិវឌ្ឍន៍សេដ្ឋកិច្ចទន្លេឡានឆាង-មេគង្គ" "ទំនាក់ទំនងរវាងខ្សែក្រវាត់អភិវឌ្ឍន៍សេដ្ឋកិច្ចទន្លេឡានឆាង-មេគង្គ និងរបៀងសេដ្ឋកិច្ច" "ការតភ្ជាប់ខ្សែក្រវាត់អភិវឌ្ឍន៍សេដ្ឋកិច្ចទន្លេឡានឆាង-មេគង្គ និងខ្សែក្រវាត់សេដ្ឋកិច្ចទន្លេយ៉ាងសេ" និង "ការចូលរួមកសាងខ្សែក្រវាត់អភិវឌ្ឍន៍សេដ្ឋកិច្ចទន្លេឡានឆាង-មេគង្គនៃតំបន់និរតី" ហើយមានអ្នកជំនាញការពាក់ព័ន្ធបានចូលរួមពិគ្រោះពិភាក្សាគ្នាក្នុងវេទិកានេះ។

អ្នកជំនាញការដែលមកពីភាគីផ្សេងៗបានលើកសំណើដ៏មានតម្លៃក្នុងវេទិកានេះដែលអាចជួយដោះស្រាយបញ្ហាប្រឈមសំខាន់ៗសម្រាប់ការកសាងខ្សែក្រវាត់អភិវឌ្ឍន៍សេដ្ឋកិច្ចទន្លេឡានឆាង-មេគង្គ។

អ្នកជំនាញការជាង៦០រូប ដែលមកពីស្ថាប័នរដ្ឋបាល និងឃ្លាំងគំនិតនៃខេត្តយូនណានស៊ីឈួន គួយចូវ ក្វាងស៊ី និងក្រុងឈុងឈីងជាដើមបានអញ្ជើញចូលរួមក្នុងវេទិកានេះ៕ **ដោយលីហុងហ៊ឹង**

**-អត្ថបទបន្ថែម**

កិច្ចសហប្រតិបត្តិការទន្លេ ឡានឆាង-មេគង្គបានត្រូវគេហៅកាត់ថា"កិច្ចសហប្រតិបត្តិការឡានមេ"។នេះជាយន្តការសហប្រតិបត្តិការបែបថ្មីដែលរួមគ្នាប្រកាសដោយប្រទេសចិនកម្ពុជា ឡាវមីយ៉ាន់ម៉ាថៃនិងវៀតណាម ក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំកំពូលស្តីពីកិច្ចសហប្រតិបត្តិការទន្លេឡានឆាង-មេគង្គលើកទី១ ដែលរៀបចំនៅក្រុងសានយ៉ាខេត្តហៃណាន នាថ្ងៃទី២៣ ខែមីនាឆ្នាំ២០១៦ ។

នៅថ្ងៃទី១០ខែមករា ឆ្នាំ២០១៨ ថ្នាក់ដឹកនាំនៃប្រទេសទាំង ៦ បានឯកភាពគ្នាលើការកំណត់យកសប្តាហ៍នៃថ្ងៃទី២៣ ខែមីនា ជារៀងរាល់ឆ្នាំជា "សប្តាហ៍ទន្លេឡានឆាង-មេគង្គ" ក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំកំពូលស្តីពីកិច្ចសហប្រតិបត្តិការទន្លេឡានឆាង-មេគង្គលើកទី២ ដែលរៀបចំនៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ ។ ក្រសួងការបរទេសចិនបានរៀបចំកម្មវិធី "សប្តាហ៍ឡានឆាង-មេគង្គ" លើកទី២ ក្នុងអំឡុងពេលពីថ្ងៃទី១៨ដល់ទី២៤ ខែមីនា ឆ្នាំ២០១៩។ វេទិកានេះជាសកម្មភាពសំខាន់មួយនៃកម្មវិធី "សប្តាហ៍ឡានឆាង-មេគង្គ"។